ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងរដ្ឋប្បវេណី
លេខ: ១៤៨/២៩-០៤-២០១៣
សាលដីកា
លេខ:១៥ ក្រVត/២៥-០៦-២០១៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ។

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

-ដើមចោទឈ្មោ [redacted] មនោរិទ្ធ ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិពោធិសែនស្នាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។(ដើមបណ្តឹងឧទ្ធរណ៍)

-ចុងចំលើយឈ្មោះ [redacted] សេរីកញ្ញា ភេទស្រី អាយុ៣១ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិពោធិសែនស្នាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ។ (ចុងបណ្តឹងឧទ្ធរណ៍)

**អង្គហេតុនិងចំណុចទទាស**

ដើមចោទឈ្មោ [redacted] មនោរិទ្ធប្តឹង៖

១.សុំលែងលះពីប្រពន្ធឈ្មោះ [redacted] សេរីកញ្ញា ឲ្យបានដាច់ស្រឡះចាប់ពីថ្ងៃនេះតទៅ ។

២.សុំសិទ្ធិគ្រប់គ្រងកូន ឈ្មោះ [redacted] ហេងហេង ភេទស្រី អាយុ១៤ឆ្នាំ និង ឈ្មោះ [redacted] វិជ្ជាត ភេទប្រុស អាយុ១២ឆ្នាំ ។

៣.សុំបែងចែកទ្រព្យរួមមាន:ផ្ទះថ្មក្រោមឈើខាងលើទំហំ៧ម៉ែត្រ គុណ២៤ម៉ែត្រ ដែលសង់នៅលើដីលំនៅដ្ឋានទំហំ១០ម៉ែត្រ គុណ ៣០ម៉ែត្រ ស្ថិតនៅភូមិពោធិសែនស្នាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ។ រថយន្តម៉ាកក្លូឡាពណ៌ក្រហមផលិតនៅឆ្នាំ២០០១ ស្លាកលេខភ្នំពេញ 2R-

៣៦១

15/2

0087 តម្លៃ១០៥០០ដុល្លារអាមេរិក ដែលប្រពន្ធជាអ្នកគ្រប់គ្រងសព្វថ្ងៃ ។ ផ្ទះសំណាក់យ៉ហោឈានឡើងទំហំ១១ម៉ែត្រគុណ២៨ម៉ែត្រ និងបន្ទប់ខាត់អូខេ ដែលសង់លើដីលំនៅដ្ឋានទំហំ២១ម៉ែត្រ គុណ៦០ម៉ែត្រ ស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ ។ ដីលំនៅស្ថានទំហំ២១ម៉ែត្រ គុណ៦០ម៉ែត្រ ស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ ។

៤.បំណុលរួមមាន ៖

ក.ជំពាក់បងប្អូន ចំនួន ៤៨.៨៤២ ដុល្លារអាមេរិក

ខ-បងឡាសំណាង ចំនួន ៤.០០០ ដុល្លារអាមេរិក

គ-បងសាន ចំនួន៩.៥០០ ដុល្លារអាមេរិក

ឃ-បងរ៉ុ ចំនួន១.៨០០ ដុល្លារអាមេរិក

ង-ធនាគារអេស៊ីលីដា ចំនួន១២.០០០ដុល្លារអាមេរិក

ច-ជំពាក់ថ្លៃភ្លើង ចំនួន៥០០ ដុល្លារអាមេរិក

ឆ-ជំពាក់បងហៃ ចំនួន៣០០ដុល្លារអាមេរិក

ជ-ជំពាក់ពូឡេឡា ចំនួន៣០០ ដុល្លារអាមេរិក

ឈ-ឈ្មោះផល ចំនួន៣០០ដុល្លារអាមេរិក

សរុបបំណុលរួម-៧៧.៥០០ ដុល្លារអាមេរិក ។

## ការអះអាងរបស់គូភាគី

១-ការអះអាងរបស់ភាគីដើមចោទៈឈ្មោះ [redacted] មនោរិទ្ធ បានឆ្លើយបញ្ជាក់ថា នៅសវនាការសាលាដំបូងមេធាវីខ្លួនពុំបានចូល ហើយខ្លួនមានមនោសញ្ចេតនាច្រើនពេកធ្វើឲ្យសម្រេចចិត្តខុស ទើបប្តឹងឧទ្ធរណ៍សុំសម្រេចជាថ្មី សុំតុលាការបែងចែកទ្រព្យរួម និង បំណុលជាពីរចំណែក ។ ពេលនេះខ្លួនឯកភាពទុកផ្ទះនិងដីទំហំ១០ម៉ែត្រx៣០ម៉ែត្រនៅខេត្តកំពង់ធំឲ្យកូន ដោយមិនទាមទារចំណុចនេះទេ។ បំណុលរួមជាង៧ម៉ឺនដុល្លារសុំឲ្យចេញសងទាំងអស់គ្នា ពីព្រោះចុងចម្លើយជាអ្នកទៅយកលុយពីម្តាយខ្លួន ។ ហើយដី និង ផ្ទះសំណាក់យ៉ហោឈានឡើងនិងបន្ទប់ការ៉ាអូខេដែលសង់លើដីទំហំ២១ម៉ែត្រគុណនឹង៦០ម៉ែត្រ សុំបែងចែកជាពីរចំណែក ។

២-ការអះអាងរបស់ភាគីចុងចម្លើយ ឈ្មោ[redacted]សេរីកញ្ញា បានឆ្លើយបញ្ជាក់ថា ខ្លួនព្រមព្រៀងឲ្យលក់ដី និង ផ្ទះសំណាក់ និងបន្ទប់ការ៉ាអូខេដែលសង់លើដីទំហំ២១ម៉ែត្រ គុណនឹង៦០ម៉ែត្រ ជាពីរចំណែក តែសុំប្រគល់ទទួលលុយចំពោះមុខខ្លួនផង ហើយក្រៅពីនេះខ្លួនសុំយកតាមការសម្រេចរបស់សាលាដំបូង ។

## សំអាងហេតុ

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៦-១២-២០១២ របស់ឈ្មោះ [redacted] មនោរិទ្ធ ប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ១៥"ក" ចុះថ្ងៃទី១៩-១២-២០១២របស់សាលាដំបូងខេត្តកំពង់ធំត្រង់ចំណុចទី៥,៦,៧,៨នៃសាលក្រម ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីសាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន។

៣៦២



Scanned with CamScanner

២-ដើមចោទបានអះអាងថា ខ្លួនបានព្រមព្រៀងដូចមានបញ្ជាក់ក្នុងសាលក្រមប្រាកដមែន ប៉ុន្តែក្រោយពីបានប្រកាសសាលក្រមរួចខ្លួនពិចារណាឡើងវិញឃើញថា មានការពិចារណាខុសមួយពេល ខ្លួនសុំឱ្យតុលាការបែងចែកទ្រព្យនិងបំណុលឡើងវិញ។

៣-ចុងចម្លើយបានឆ្លើយបដិសេធមិនព្រមធ្វើការបែងចែកឡើងវិញទេ លើកលែងតែការលក់ដីនិងផ្ទះសំណាក់នៅក្នុងចំណុចទី៥នៃសេចក្តីសម្រេច ដើម្បីយកប្រាក់មកចែកជាពីរចំណែកស្មើគ្នា។ ដើមចោទបានឯកភាពនឹងការលើកឡើងនេះ គប្បីតុលាការធ្វើការបែងចែកតាមការព្រមព្រៀង។

៤-សាលក្រមរដ្ឋប្បវេណីលេខ១៥"ក" ចុះថ្ងៃទី១៩-១២-២០១២របស់សាលាដំបូងខេត្តកំពង់ធំ បានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តំកល់សាលក្រមខាងលើទុកជាបានការ លើកលែងតែចំណុចដូចបានសំអាងហេតុទី៣ខាងលើដែលត្រូវកែតម្រូវឡើងវិញ។

## ទនិច្ឆ័យសេចក្តី

១-ច្រានចោលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៦-១២-២០១២ របស់ឈ្មោះ[redacted] មនោវិទ្ធ លើកលែងតែទី៥នៃសេចក្តីសម្រេច។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ១៥"ក" ចុះថ្ងៃទី១៩-១២-២០១២របស់សាលាដំបូងខេត្តកំពង់ធំទុកជាបានការលើកលែង តែចំណុចទី៥នៃសេចក្តីសម្រេចត្រង់ "ឱ្យដើមចោទគ្រប់គ្រងលើដីនិងផ្ទះសំណាក់យីហោឈានឡើងនិងបន្ទប់កាវ៉ាអូខេដែលសង់លើដីទំហំ២១ម៉ែត្រគុណ នឹង៦០ម៉ែត្រស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ ដើម្បីទុកឱ្យកូនទាំងពីរនៅពេលមានវ័យនីតិភាព"ត្រូវកែប្រែជា "ដីនិងផ្ទះសំណាក់យីហោឈានឡើងនិងបន្ទប់កាវ៉ាអូខេដែលសង់លើដីទំហំ២១ម៉ែត្រគុណនឹង៦០ម៉ែត្រស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿងស្រុករវៀង ខេត្តព្រះវិហារ ត្រូវបែងចែកជាពីរចំណែកស្មើគ្នារវាងដើមចោទ និងចុងចម្លើយតាមការព្រមព្រៀងរបស់គូភាគី"។

ដីមួយកន្លែងទៀតក្នុងចំណុចទី៥ និងចំណុចផ្សេងទៀតនៃសេចក្តីសម្រេចនៅរក្សាទុកជាបានការដដែល។

៣-ប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ជាបន្ទុករបស់ឈ្មោះ[redacted] មនោវិទ្ធ។

សាលដីកានេះទាញហេតុផលដោយផ្ទាល់មាត់ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១៣ ។ គូភាគីមានសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេល១ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

ក្រឡាបញ្ជី ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សា

ហត្ថលេខា [redacted]

.................................................................................................

បានឃើញ

ប្រធានក្រុមប្រឹក្សា

[redacted]

៣៦៣

ច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 30 ខែកក្កដា ឆ្នាំ ២០១៣

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner